## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខៈ 15 PR-17/EoJ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

## ស្តីពីលិខិតសរសើររបស់រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន

នៅថ្ងៃទី២៩ ខែមិថុនា ក្រសួងការបរទេសជប៉ុន បានចេញសេចក្តីប្រកាសព័ត៌មានស្តីអំពីលិខិតសរសើររដ្ឋមន្ត្រីការបរទេសជូនចំពោះបុគ្គល ឬក្រុមដែលមានស្នាដៃឆ្នើមលើវិស័យអន្តរជាតិក្នុងឆ្នាំនេះ ដើម្បីជាការទទួលស្គាល់នូវការរួមចំណែករបស់ពួកគេលើការជម្រុញនូវចំណងមិត្តភាពរវាងជប៉ុន និងបណ្តាប្រទេសនានា។

បុគ្គលឆ្នើមនៃប្រទេសកម្ពុជាដែលទទួលបានលិខិតសរសើរចំពោះសកម្មភាពនានារបស់សាមីខ្លួនមានដូចខាងក្រោមៈ

- **ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
  ឯកឧត្តមបណ្ឌិត ជេត ជាលី ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចូលរួមចំណែកជម្រុញការផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យជាច្រើននៃប្រទេសជប៉ុន។ បច្ចុប្បន្ននេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះអនុស្សារណៈយោគយល់ជាមួយនិងសាកលវិទ្យាល័យចំនួន៣៣នៃប្រទេសជប៉ុន។

- **ឯកឧត្តមបណ្ឌិត ហោ ប៉េង សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង**
  ខណៈពេលដែលឯកឧត្តមបណ្ឌិត ហោ ប៉េង ជាព្រឹទ្ធបុរស មហាវិទ្យាល័យរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកឧត្តមបណ្ឌិតបានជួយដល់ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំច្បាប់ជប៉ុនរបស់សាកលវិទ្យាល័យណាហ្គូយ៉ា នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបានចូលរួមចំណែកដល់មជ្ឈមណ្ឌលនេះឲ្យមានដំណើរការយ៉ាងរលូន។

ក្រោយពី ឯកឧត្តមបណ្ឌិត ទទួលតំណែងជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ឯកឧត្តមបណ្ឌិត បានចូលរួមចំណែកជម្រុញការផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យមួយចំនួននៃប្រទេសជប៉ុនផងដែរ។

ពិធីប្រគល់លិខិតសរសើរនឹងត្រូវបានរៀបចំក្នុងពេលឆាប់ៗខាងមុខនេះ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162; Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*